**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ** ១១៣៤ សជណ

*រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣*

**ជូនចំពោះ**

**លោក ពេជ អង្គ និង លោកស្រី** Elisabeth SIMONNEAU FORT
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង00២**

**កម្មវត្ថុៈ** ករណីសំណើសុំសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការរៀបចំគម្រោងសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងករណី ០០២។

**យោងៈ** - លិខិតលេខ LCLs-2013-00014 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១៣ របស់អង្គភាពសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

- ចំណាររបស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៣

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើទីស្តីការគណៈរដ្ឋមន្ត្រីជម្រាប លោក លោកស្រី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជ្រាបថា រាជរដ្ឋាភិបាលបានឯកភាពដូចខាងក្រោមៈ

- ផ្តល់ការអនុញ្ញាតជាគោលការណ៍តាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។
- កំណត់យកថ្ងៃទី២០ ឧសភា ជា ***ទិវាជាតិនៃការចងចាំ*** នៅក្នុងប្រក្រតិទិនឈប់សម្រាកប្រចាំឆ្នាំជំនួសទិវាចងកំហឹង ឬទិវារំលឹកវិញ្ញាណក្ខន្ធ ដែលបាននិងកំពុងប្រើប្រាស់ចាប់តាំងពីឆ្នាំ១៩៨៤ រហូតមកដល់សព្វថ្ងៃនេះ។
- ឯកភាពឲ្យមានការចងក្រងឯកសារប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យ និងដាក់បញ្ចូលជាផ្នែកមួយក្នុងកម្មវិធីសិក្សាចាប់ពីថ្នាក់ចំណេះដឹងទូទៅពីថ្នាក់ទី ៧ ដល់ទី ១២ និងនៅថ្នាក់មូលដ្ឋាននៃកម្មវិធីសិក្សាថ្នាក់ឧត្តមសិក្សា។
- សម្រាប់គម្រោងសំណង និងវិធានការទាំងនេះ រាជរដ្ឋាភិបាលនឹងចេញជាអនុក្រឹត្យ សារាចរណែនាំ ឬសេចក្តីជូនដំណឹងដល់ស្ថាប័នពាក់ព័ន្ធនានា យោងទៅតាមកម្មវត្ថុនីមួយៗ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងទេសចរណ៍ និងអាជ្ញាធរដែនដី ខណ្ឌ-ស្រុក រាជធានី-ខេត្ត ក្រុង។
- ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ត្រូវទទួលភារកិច្ចបន្តស្វែងរកការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់អនុវត្តគម្រោងសំណង និងវិធានការដែលបានស្នើសុំខាងលើ។

សេចក្តីដូចបានជម្រាបខាងលើ សូមលោក លោកស្រីជ្រាបជាព័ត៌មាន។

សូមលោក និងលោកស្រីសហមេធាវី ទទួលនូវការរាប់អានពីខ្ញុំ។

**ជ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

Thoraxy

**ហ៊ីង ថូរ៉ាក់ស៊ី**

**ចម្លងជូនៈ**
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
- ឯកសារ-កាលប្បវត្តិ